# ការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយនៅ អ.វ.ត.ក : សេចក្តីសន្និដ្ឋាន

*ដោយ ម៉ៃទឹល សាលីបា*

*ថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានប្រឈមមុខនឹងការព្រួយបារម្ភពីការជ្រៀតជ្រែកផ្នែកនយោបាយអស់រយៈពេលយ៉ាងយូរមកហើយ ។ កត្តាចម្បងនៃភាពចម្រូងចម្រាស់នេះ គឺជាការចោទប្រកាន់ដែលថា រដ្ឋាភិបាលកម្ពុជាបានកំពុងដាក់ឥទ្ធិពលយ៉ាងច្រើនមកលើសហព្រះរាជអាជ្ញាជាតិ និងបុគ្គលិកកម្ពុជារបស់តុលាការ ដែលត្រូវធ្វើតាមសេចក្តីសម្រេចរបស់រដ្ឋាភិបាលណែនាំ ។ ភាពចម្រូងចម្រាស់នេះ បានកើតឡើងសារជាថ្មីម្តងទៀតនាពេលថ្មីៗនេះ ខណៈពេលដែលអង្គជំនុំជម្រះសម្រេចបញ្ចប់ការជាប់គាំងដែលមានរយៈពេល៩ខែកន្លងមកនេះ ដោយអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអន្តរជាតិធ្វើការស្នើសុំជាផ្លូវការសម្រាប់ការស៊ើបអង្កេតលើជនសង្ស័យបន្ថែមទៀត សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ជម្លោះទាក់ទិននឹងការស៊ើបអង្កេតលើឧក្រិដ្ឋជនបន្ថែម បានដាក់ជូនចំពោះអង្គជំនុំជម្រះជាផ្លូវការកាលពីខែធ្នូ ឆ្នាំ២០០៨ ពេលដែល រ៉ូបឺត ពើទីត បានដាក់សេចក្តីសន្និដ្ឋាននៃការមិនព្រមព្រៀងគ្នារវាងសហព្រះរាជអាជ្ញាទាំងពីរជូនអង្គបុរេជំនុំជម្រះ ។ រ៉ូបឺត ពើទីត មានគោលបំណងបើកដំណើរការស៊ើបអង្កេតរបស់តុលាការលើមេដឹកនាំខ្មែរក្រហមមួយចំនួនបន្ថែមទៀត ប៉ុន្តែសកម្មភាពបែបនេះត្រូវបានជំទាស់ដោយ ជា លាង សហព្រះរាជអាជ្ញាជាតិ ។ ក្នុងចំណោមអំណះអំណាងតាមផ្លូវច្បាប់ជាច្រើននោះ លោកស្រីបានលើកឡើងពីការព្រួយបារម្ភយ៉ាងខ្លាំងពីបញ្ហាសន្តិភាព និងស្ថេរភាពរបស់ប្រទេសកម្ពុជា ប្រសិនបើការស៊ើបអង្កេតលើជនសង្ស័យបន្ថែមទៀតនេះត្រូវបានធ្វើឡើង ។

មតិអ្នករិះគន់បានអះអាងថា គោលជំហររបស់ ជា លាង ធ្វើឡើងដោយមិនផ្អែកលើការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងនាមជាព្រះរាជអាជ្ញាឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺបណ្តាលមកពីឥទ្ធិពលនយោបាយដែលទទួលបានពីសំណាក់រដ្ឋាភិបាលកម្ពុជា ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការរិះគន់ជាសាធារណៈលើកិច្ចខិតខំប្រឹងប្រែងព្យាយាមឲ្យកាត់ទោសជនសង្ស័យបន្ថែម

លើសពីជនត្រូវចោទចំនួនប្រាំរូបដែលកំពុងតែធ្វើការជំនុំជម្រះសេចក្ដី ឬត្រៀមជំនុំជម្រះសេចក្ដី ។ សម្ដេច ហ៊ុន សែន បានគម្រាមថាភាពវឹកវរក្នុងសង្គម និងសង្គ្រាមស៊ីវិលអាចកើតមានឡើង ។ សម្ដេចបានណែនាំថា ជនទាំងឡាយណាដែលមានគោលបំណងចង់ធ្វើការកាត់ទោសបន្ថែមនឹងតែត្រូវទទួលខុសត្រូវចំពោះភាពវឹកវរដែលអាចកើតមានឡើងនោះ ។ សម្ដេចបានអះអាងថា សន្ដិភាពដែលមានសភាពទ្រុឌទ្រោមរបស់ប្រទេសកម្ពុជា ដែលកកើតឡើងនៅពេលខ្មែរក្រហមបានចុះចូលជាមួយនឹងរដ្ឋាភិបាលអាចនឹងរងនូវគ្រោះថ្នាក់ ប្រសិនបើអតីតខ្មែរក្រហមដែលចូលរួមនៅក្នុងចលនានេះចាប់ផ្ដើមមានភាពភ័យខ្លាចចំពោះការកាត់ទោស ។ យ៉ាងណាមិញ ការគូសបញ្ជាក់ដែលថា ប្រទេសកម្ពុជាអាចនឹងប្រឈមមុខនឹងសង្គ្រាមស៊ីវិលនោះ ត្រូវបានបដិសេធមិនយល់ស្របពីសំណាក់មនុស្សជាច្រើនដែលមានការយល់ដឹងពីស្ថានភាពរបស់ប្រទេសកម្ពុជា ។ ជាមួយគ្នានេះ អ្នកទាំងនោះបានអះអាងថា គ្មានអ្វីដែលគួរតែធ្វើការក្រើនរំឭកទាក់ទិននឹងភាពដែលអាចកើតមានឡើងនូវសង្គ្រាមស៊ីវិលនោះទេ ។

សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានចេញសេចក្ដីចោទប្រកាន់ប្រហាក់ប្រហែលគ្នានេះលើចៅក្រម និងព្រះរាជអាជ្ញាអន្ដរជាតិ ។ សម្ដេចបានចោទប្រកាន់លើសេចក្ដីបង្គាប់បញ្ជារបស់រដ្ឋាភិបាលនៃសហគមន៍អន្ដរជាតិនៅឯអង្គជំនុំជម្រះក្នុងការចេញសេចក្ដីសម្រេច ដែលអាចនឹងបង្កឲ្យមានភាពវឹកវរ និងអស្ថេរភាពក្នុងប្រទេសកម្ពុជា ។ សម្ដេចបានអះអាងថា ការបង្កឲ្យមានការបែកខ្ញែកសង្គមកម្ពុជា អាចធ្វើឲ្យរដ្ឋាភិបាលនៃសហគមន៍អន្ដរជាតិមានភាពងាយស្រួលក្នុងការក្ដោបក្ដាប់ប្រទេសកម្ពុជា ។ លោកអនុប្រធានផ្នែករដ្ឋបាលរបស់ អ.វ.ត.ក បានឆ្លើយតបថា លោកមិនមានហេតុផលដែលគិតថា ការចោទប្រកាន់ទាំងនោះក៏មានចំណុចល្អខ្លះនោះទេ ។ លោកសង្ឃឹមថាទាំងបុគ្គលិកជាតិនិងអន្ដរជាតិរបស់ អ.វ.ត.ក អាចបំពេញតួនាទីរបស់ខ្លួនដោយមិនមានការជ្រៀតជ្រែកពីផ្នែកនយោបាយ ហើយលោកក៏បានបញ្ជាក់ម្ដងទៀតថាតាមគោលការណ៍នៃការបង្កើតតុលាការនេះឡើង អង្គសវនាការរបស់តុលាការនេះមិនតម្រូវឲ្យមានការអនុញ្ញាតពីអំណាចនីតិប្រតិបត្តិឡើយ ។

អ្នកឃ្លាំមើលសិទ្ធិមនុស្ស បានចាត់ទុកប្រតិកម្មរបស់សម្ដេចនាយករដ្ឋមន្ត្រីចំពោះការស៊ើបអង្កេតលើជនសង្ស័យបន្ថែមទៀតថាជាគោលបំណងដាក់ឥទ្ធិពលលើកិច្ចការរបស់តុលាការ ហើយបានបញ្ជាក់ពីការចោទប្រកាន់ពីមុនរបស់សម្ដេចនាយករដ្ឋមន្ត្រីថា សម្ដេច ហ៊ុន សែន កំពុងតែព្យាយាមប្រើប្រាស់អំណាចរបស់ខ្លួនទៅលើបុគ្គលិកកម្ពុជាដើម្បីជ្រៀតជ្រែកក្នុងកិច្ចការរបស់តុលាការ ។ នោះគឺជាការចោទប្រកាន់មួយខ្សែទាក់ទិននឹងការជ្រៀតជ្រែកផ្នែកនយោយបាយ ដែលត្រូវបានធ្វើឡើងដោយអ្នកឃ្លាំ

មើលដំណើរការរបស់តុលាការ ។ របាយការណ៍មួយដែលរៀបចំដោយអ្នកផ្តួចផ្តើមសង្គមយុត្តិធម៌បើកចំហរបានចោទប្រកាន់ថា រដ្ឋាភិបាលកម្ពុជាកំពុងមានបំណងរារាំងចៅក្រមស៊ើបអង្កេតមិនឲ្យជួបសម្ភាសន៍ជាមួយនឹង«ជនផ្ទៃក្នុង» ឬ«សាក្សីដែលមានមុខតំណែងខ្ពស់» ដែលជនទាំងអស់នេះប្រហែលជាជនមានអំណាច ។ ហើយអ្នកទាំងនោះអាចនឹងមានភាពអាម៉ាស់ក្នុងការមកធ្វើកសិណសាក្សីស្តីពីការចូលរួមរបស់ខ្លួនជាមួយនឹងខ្មែរក្រហម ។ លើសពីនេះ កាលពីខែមិថុនា មេធាវីការពារក្តីរបស់ នួន ជា បានបញ្ជាក់ថាភាគីរបស់ខ្លួនបានជ្រាបដំណឹងដែលគួរឲ្យជឿជាក់បានថាសហព្រះរាជអាជ្ញាជាតិ បានទទួលការបង្គាប់បញ្ជាពីរដ្ឋាភិបាលកម្ពុជាក្នុងការមិនបន្តឲ្យមានការកាត់ទោសបន្ថែម ។

វាពិតជាប្រាកដណាស់ថា សម្តេចនាយករដ្ឋមន្ត្រីប្រឆាំងនឹងការកាត់ទោសលើជនសង្ស័យបន្ថែមទៀត ។ យ៉ាងណាមិញ វាមិនប្រាកដប្រជាថាតើសេចក្តីជំទាស់របស់សម្តេចនាយករដ្ឋមន្ត្រីកើតចេញពីការព្រួយបារម្ភដែលត្រឹមត្រូវតាមផ្លូវច្បាប់ទាក់ទិននឹងសន្តិសុខក្នុងប្រទេស ឬក៏កើតចេញពីគោលដៅនយោបាយ ។ ដើម្បីឲ្យប្រាកដ មានមូលដ្ឋានជាច្រើនដែលបុគ្គលម្នាក់អាចជំទាស់នឹងការកាត់ទោសលើជនសង្ស័យបន្ថែមទៀត ។ ឧទាហរណ៍ ដោយសារតែឧក្រិដ្ឋកម្មមានលក្ខណៈរាលដាលនោះអង្គជំនុំជម្រះមិនអាចនឹងធ្វើការកាត់ទោសជនទាំងអស់ដែលមានការទទួលខុសត្រូវនោះទេ ដូច្នេះការកាត់ទោសលើចំនួនជនសង្ស័យបន្ថែមចុងក្រោយនោះអាចចាត់ទុកថា ជាការរំលោភបំពាន ។ ហេតុនេះហើយមនុស្សជាច្រើនជឿថា វាគឺជាការប្រសើរក្នុងការកាត់ទោសជនដែលដល់ដែលកំពុងតែជាប់ឃុំឃាំង ដើម្បីធ្វើជាទម្រង់នៃយុត្តិធម៌ជានិមិត្តសញ្ញា និងដើម្បីបង្កើតយន្តការមួយទៀតដែលមានប្រសិទ្ធិភាពជាងនេះដើម្បីកាត់ទោសជនសង្ស័យផ្សេងទៀត ។

វាមិនមានភាពប្រាកដប្រជាថា តើសម្តេចនាយករដ្ឋមន្ត្រីមានឥទ្ធិពលលើបុគ្គលិករបស់តុលាការតាមរយៈសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់លោកដែរឬយ៉ាងណានោះទេ ។ ភាពសុច្ចរិតផ្លូវច្បាប់ និងឯករាជ្យភាពរបស់ អ.វ.ត.ក ចេញពីការជ្រៀតជ្រែកពីផ្នែកនយោបាយ គឺជាលក្ខខណ្ឌិកៈដ៏ចម្បង ដើម្បីធានាឲ្យបាននូវតុលាការកាត់ទោសដែលប្រកបដោយយុត្តិធម៌ និងភាពមិនលំអៀងស្របតាមបទដ្ឋានដំណើរការនីតិវិធីអន្តរជាតិ ។